មើលវីដេអូ ចេតសិកនិងចិត្ត ភាគទី ១០

# ៥ - លោភចេតសិក (Attachment)

លុព្ភតីតិ = លោភោ ឈ្មោះថា លោភៈ ព្រោះអត្ថថា ចង់បាន។

លុព្ភន្តិ សម្បយុត្តា ធម្មា ឯតេនាតិ = លោភោ សភាវធម៌ធ្វើឲ្យ

សម្បយុត្តធម៌ចង់បាន។ លោភៈនេះ កើតជាមួយនឹង

លោភមូលចិត្ត ៨ ដួង ប៉ុណ្ណោះ។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# លក្ខណាទិចតុក្កៈរបស់លោភៈ

១ - អារម្មណគ្គហណលក្ខណោ មានការកាន់យកនូវអារម្មណ៍ជាលក្ខណៈ ដូចស្វាជាប់ជ័រ

២ - អភិសំគរសោ មានការជាប់ជំពាក់នឹងអារម្មណ៍ ជាកិច្ចដូចដុំសាច់ដែលដាក់លើអំបែងក្តៅ

៣ - អបរិច្ចាគបច្ចុប្បដ្ឋានោ មានការមិនលះបង់ ជាអាការប្រាកដដូចសំពត់ប្រឡាក់ប្រេង ឬទឹកថ្នាំពណ៌

៤ - សំយោជនីយធម្មេសុ អស្សាទទស្សនបទដ្ឋានោ មានការមើលដោយសេចក្តីគាប់ចិត្ត ក្នុងធម៌ដែលជាអារម្មណ៍របស់សំយោជនៈ ជាហេតុជិត។

ក្នុងបរមត្ថទីបនី បានរៀបរាប់អំពីវេវចនៈ នៃលោភៈ មាន ១០ យ៉ាងគឺ ៖

| | |
|---|---|
| ១ - តណ្ហា | ចំណង់ |
| ២ - រាគៈ | តម្រេក |
| ៣ - កាមៈ | សេចក្តីប្រាថ្នា ឬស្រឡាញ់ |
| ៤ - នន្ទិ | សេចក្តីរីករាយ ភ្លើតភ្លើន |
| ៥ - អភិជ្ឈា | ការសំឡឹងរំពៃ |
| ៦ - ជនេត្តី | អ្នកបង្កើត |
| ៧ - បោនោព្ភវិកា | អ្នកឲ្យកើតក្នុងភពថ្មី |
| ៨ - ឥច្ឆា | សេចក្តីប្រាថ្នាចង់បាន |
| ៩ - អាសា | ការប៉ុនប៉ង ឬសង្ឃឹម |
| ១០ - សញ្ញោជនៈ | គ្រឿងចង។ |

## ៦ - ទិដ្ឋិចេតសិក (Misbelief or Wrong View)

ទស្សនំ = ទិដ្ឋិ សេចក្ដីយល់ឃើញ ឈ្មោះថា ទិដ្ឋិ។ ទិដ្ឋិក្នុងទីនេះ សំដៅយកតែមិច្ឆាទិដ្ឋិប៉ុណ្ណោះ។

# ទិដ្ឋិ មាន ២ យ៉ាង ៖

១ - **សាមញ្ញទិដ្ឋិ** បានដល់ សក្កាយទិដ្ឋិដែលមានសេចក្ដីយល់ខុសចាកសភាវធម៌ថា "ជាមនុស្ស ជាសត្វ ជាអត្តា"។ ទិដ្ឋិនេះ មានទូទៅសម្រាប់បុថុជ្ជន វៀរលែងតែ ព្រះអរិយៈប៉ុណ្ណោះ ទើបហៅថា **សាមញ្ញទិដ្ឋិ**។

២ - **ទិដ្ឋិវិសេស** បានដល់ ទិដ្ឋិ ៦២ និងនិយតមិច្ឆាទិដ្ឋិជាដើម (វៀរសក្កាយទិដ្ឋិ) ព្រោះទិដ្ឋិនេះមានចំពោះមនុស្សពួកខ្លះ និងឱកាសខ្លះប៉ុណ្ណោះ។

# លក្ខណាទិចតុក្កៈរបស់ទិដ្ឋិ

| | |
|---|---|
| ១ - អយោនិសោ អភិនិវេសលក្ខណា | មានការប្រកាន់ទុក ដោយមិនត្រូវទំនង ជាលក្ខណៈ |
| ២ - បរាមាសរសា | មានការស្ទាបអង្អែលខុសពីសភាវៈ ជាកិច្ច |
| ៣ - មិច្ឆាភិនិវេសនបច្ចុប្បដ្ឋានា | មានការប្រកាន់មាំ ក្នុងផ្លូវខុស ជាអាការប្រាកដ |
| ៤ - អរិយានំ អទស្សនកាមតាទិ បទដ្ឋានា | មានការមិនចង់ឃើញព្រះអរិយៈជាដើម ជាហេតុជិត។ |

# ៧ - មានចេតសិក (Conceit)

សេយ្យោហមស្មីតិ អាទិនា មញ្ញតីតិ = មានោ ឈ្មោះថា មានៈ ព្រោះអត្ថថា សំគាល់ខ្លួនដោយលក្ខណៈ មានជាដើមថា  "យើងជាអ្នកប្រសើរជាងគេ" ដូច្នេះ ជាដើម។

# មានៈ មាន ២ យ៉ាង

មានៈ ដែលព្រះសោតាបន្នលះ ហៅថា អយាថាវមានៈ

មាន ៦ គឺ ៖

| | | |
|---|---|---|
| ១ - ល្អជាងគេ | សំគាល់ខ្លួនថា | ស្មើនឹងគេ |
| ២ - ល្អជាងគេ | សំគាល់ខ្លួនថា | ទាបជាងគេ |
| ៣ - ស្មើនឹងគេ | សំគាល់ខ្លួនថា | ល្អជាងគេ |
| ៤ - ស្មើនឹងគេ | សំគាល់ខ្លួនថា | ទាបជាងគេ |
| ៥ - ទាបជាងគេ | សំគាល់ខ្លួនថា | ល្អជាងគេ |
| ៦ - ទាបជាងគេ | សំគាល់ខ្លួនថា | ស្មើនឹងគេ។ |

មានៈ ដែលព្រះអរហន្តលះ ហៅថា យាថាវមានៈ

មាន ៣ គឺ ៖

១ - ល្អជាងគេ សំគាល់ថា ល្អជាងគេ

២ - ស្មើនឹងគេ សំគាល់ថា ស្មើនឹងគេ

៣ - ទាបជាងគេ សំគាល់ថា ទាបជាងគេ។

## ម្យ៉ាងទៀត មានៈ មានវេវចនៈ ច្រើនយ៉ាងដូច្នេះ គឺ ៖

១ - ឈ្មោះថា អតិមានៈ ការមើលងាយ បន្តុះបង្អាប់អ្នកដទៃ

២ - ឈ្មោះថា មានាតិមានៈ សេចក្តីឆ្មើងកន្ទ្រើង ក្រអឺតក្រទម

៣ - ឈ្មោះថា ឱមានៈ ការប្រកាន់ដ៏ថោកទាប

៤ - ឈ្មោះថា អធិមានៈ សំគាល់ថា សម្រេចធម៌វិសេស

៥ - ឈ្មោះថា អស្មិមានៈ សំគាល់ថា មានអត្តា (មានតែអញ)

៦ - ឈ្មោះថា មិច្ឆាមានៈ សំគាល់ខុស។

# លក្ខណាទិចតុក្កៈរបស់មានៈ

១ -ឧន្នតិលក្ខណោ — មានការលើកខ្លួន *(អួតខ្លួន)* ជាលក្ខណៈ

២ - សម្បគ្គហរសោ — មានការលើកតម្កើងខ្លួន *(ប្រកាន់ឫក)* ជាកិច្ច

៣ - កេតុកម្យតាបច្ចុប្បដ្ឋានោ — មានសេចក្តីត្រូវការខ្ពស់ ដូចជាទង់ ជាអាការប្រាកដ

៤ - ទិដ្ឋិវិប្បយុត្តលោភបទដ្ឋានោ — មានលោភៈ មិនប្រកប ដោយទិដ្ឋិ ជាហេតុជិត។